# សិក្ខាសាលារៀបចំយុទ្ធសាស្ត្របណ្តាញកសិករ និងធម្មជាតិ

បណ្តាញកសិករ និងធម្មជាតិបានរៀបចំសិក្ខាសាលរៀបចំយុទ្ធសាស្ត្របណ្តាញនៅថ្ងៃទី ០៩ -១០ ខែតុលា ឆ្នាំ ២០០៨ នៅវិទ្យាស្ថានសេដាកដើម្បីអភិវឌ្ឍន៍មូលដ្ឋាន (CILD) ។ សិក្ខាសាលានេះសម្របសម្រួលដោយប្រធានអង្គការសេដាក បណ្ឌិត **យ៉ង សាំងកុមារ** និងលោក **គាត់ សុខ** ហើយមានអ្នកចូលរួមសរុបចំនួន ២៦ នាក់ ក្នុងនោះមាន ៩ នាក់ជាស្ត្រី។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំនងដើម្បី:



- ចែករំលែកបទពិសោធន៏ការងារនៅតាមតំបន់មូលដ្ឋាន
- ឆ្លុះបញ្ចាំងពី ភាពរីកចំរើននៅតាមតំបន់មូលដ្ឋាន
- រៀបចំយុទ្ធសាស្ត្របណ្តាញអោយកាន់តែរឹងមាំ

ក្នុងកំឡុងពេលពីរថ្ងៃនៃសិក្ខាសាលានេះ នៅថ្ងៃទី ១ អ្នកសម្របបសម្រួលបានចាក់រឿងមហាត្មាសគន្ធី ឱ្យអ្នកចូលរួមទស្សនា ហើយបានធ្វើការឆ្លុះបញ្ចាំងពីតួអង្គនៅក្នុងរឿងនេះ ដោយចែកក្រុមពិភាក្សាវិភាគទៅលើចំនុចសំខាន់ៗដូចជា:

- ចំនុចខ្លាំង និងចំនុចខ្សោយរបស់តួអង្គសំខាន់ៗ?
- យុទ្ធសាស្ត្ររបស់តួអង្គដើម្បីរំដោះខ្លួនចេញរួចពីអាណានិគមអង់គ្លេសបាន? និង
- អ្វីដែលគិតថា ជាចំនុចល្អហើយគួរធ្វើតាមជាដើម ។ល ។

នៅថ្ងៃទី២អ្នកសម្របសម្រួលអោយអ្នកចូលរួមចែករំលែកបទពិសោធន៍ និងភាពរីកចំរើននៅតាមតំបន់រៀងៗខ្លួន ព្រមទាំងអោយសរសេរពីភាពរីកចំរើនលើអ្វីមួយអោយជាក់លាក់ពីមុន និងឥឡូវ ។

នៅចុងបញ្ចប់អ្នកចូលរួមបានធ្វើការចាប់អារម្មណ៏ ដោយបញ្ជាក់ថាពួកគាត់បានទទួលនូវអ្វីដែលថ្មីដែលអាចយកទៅធ្វើតាមបានគឺ ការយកតំរាប់តាមតួអង្គមហាត្មាសគន្ធី មានចិត្តតស៊ូ អំណត់ ក្លាហាន មានជំនាញច្បាស់លាស់ និងការរស់នៅជាសហគមន៏ស្មើភាពគ្នា មិនប្រកាន់ពណ៌សំបុរ ហើយមានការសហការគ្នា ។ ចំណែកអនុសាសន៏ ឬ ក៏ជាគំនិតថ្មីៗ ទាក់ទងនឹងការងារគាំទ្រសមាគមកសិករនៅតាមមូលដ្ឋានវិញគឺ ការក្តាប់ពីស្ថានភាពនៅតាមតំបន់រៀងៗខ្លួន និងការរៀបចំមនុស្សជំហរដើម្បីផ្តល់សេវាកម្មនៅតាមមូលដ្ឋានដើម្បីធ្វើអោយពួកគេកាន់តែមានភាពងាយស្រួល និងល្អប្រសើរឡើង ។